**ការិយាល័យរដ្ឋបាល**

មកដល់ថ្ងៃទី 29.07 ម៉ោង ...
លេខ ... សខ.ទ
អ្នកទទួល ... ហត្ថលេខា ...
អ្នកប្រគល់ ... ហត្ថលេខា ...
បញ្ជូនទៅ ...

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូល កម្ពុជា_ឡាវ_វៀតណាម លើកទី៦ (6th CLV Summit) កម្ពុជា_ឡាវ_មីយ៉ាន់ម៉ា_វៀតណាម លើកទី៥ (5th CLMV Summit) និង យុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី_ចៅប្រាយ៉ា_មេគង្គ លើកទី៤ (4th ACMECS Summit) ឆ្នាំ ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូល កម្ពុជា-ឡាវ-វៀតណាម លើកទី៦ (6th CLV Summit) កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី៥ (5th CLMV Summit) និងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ លើកទី៤ (4th ACMECS Summit) ឆ្នាំ ២០១០ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | **ប្រធាន** |
| ២-ឯកឧត្ដម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | **អនុប្រធាន** |
| ៣-ឯកឧត្ដម **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | **អនុប្រធាន** |

៤-ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី **អនុប្រធាន**

៥-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **អនុប្រធាន**

៦-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

៧-ឯកឧត្តម **អ៊ុច សារ៉ាន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

៨-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា **សមាជិក**

៩-ឯកឧត្តម **យឹម សារិទ្ធ** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **សមាជិក**

១០-ឯកឧត្តម **តែ គុយសៀង** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល **សមាជិក**

១១-ឯកឧត្តម **កែប ជុតិមា** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ **សមាជិក**

១២-ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត្រ សាវឿន** អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ **សមាជិក**

១៣-ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

១៤-ឯកឧត្តម **ជា សុខុម** អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ គ.ជ.ប.អ **សមាជិក**

១៥-លោកជំទាវ **ធូត បញ្ញា** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

១៦-ឯកឧត្តម **ហោ សុធន** អគ្គលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

១៧-លោក ឧត្តមសេនីយ៍ឯក **ស៊ូ ឆាន** ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ **សមាជិក**

១៨-លោក **ធួន ស៊ីផាន់** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី **សមាជិក**

**ប្រការ ២ :** គណៈកម្មការរៀបចំកិច្ចប្រជុំកំពូលនេះ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំកម្មវិធីនៃកិច្ចប្រជុំនិងពិធីការ ឱ្យបានសមស្រប
- លើកគម្រោងចំណាយសរុប តាមក្រុមជំនាញ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- សម្របសម្រួលនិងរៀបចំការពារសន្តិសុខ ជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំ ឱ្យមានសុវត្ថិភាពល្អ
- រៀបចំពិធីសំដែងសិល្បៈ របាំប្រពៃណី ជូនគណៈប្រតិភូជាតិ និងអន្តរជាតិ
- សម្រួលចាត់ចែងកម្មវិធីដំណើរទស្សនាចរណ៍ ជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំចប់កម្មវិធី
- ជួយសម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិនិងអន្តរជាតិ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលកិច្ចប្រជុំនេះ។

**ប្រការ ៣ :** សមាជិកគណៈកម្មការខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន អនុប្រធានគណៈកម្មការ និង ត្រូវធ្វើសេចក្តីរាយការណ៍ ជូនប្រធានគណៈកម្មការ អំពីលទ្ធផលការងាររបស់ខ្លួន។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធានគណៈកម្មការរៀបចំបុណ្យជាតិនិងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*